# សៀវភៅមគ្គុទេសក៍



## ដំណើរការចុះបញ្ជីអាជីវកម្ម
## តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

ហាមថតចម្លង
រក្សាសិទ្ធិឆ្នាំ ២០២០ ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រក្សាសិទ្ធិគ្រប់យ៉ាង

បោះពុម្ពផ្សាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ ប្រទេសកម្ពុជា

**ការបោះពុម្ពលើកដំបូង**

# មាតិកា


## ផ្នែកទី ១ ព័ត៌មានទូទៅ 0៤

ហេតុអ្វីត្រូវចុះបញ្ជីអាជីវកម្ម? 0៤
ទិដ្ឋភាពរួមនៃការចុះបញ្ជីអាជីវកម្មតាមនីតិវិធីចាស់ និងថ្មី 0៥
ទម្រង់សហគ្រាស 0៧
ប្រភេទអ្នកជាប់ពន្ធ 0៩
ឯកសារភ្ជាប់ ១១
តម្លៃសេវាចុះបញ្ជីអាជីវកម្ម ១៤

## ផ្នែកទី ២ ចុះបញ្ជីអាជីវកម្មអ្នកតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ១៦

ដំណើរការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ១៦
សេវាកម្មផ្សេងទៀតក្រៅពីការចុះបញ្ជីអាជីវកម្ម ២៨
ជំនួយបន្ថែម ២៩

# ផ្នែកទី ១

# ព័ត៌មានទូទៅ



## ហេតុអ្វីត្រូវចុះបញ្ជីអាជីវកម្ម?



**០១**

បង្កើតអត្តសញ្ញាណផ្ទាល់ខ្លួន
សម្រាប់អាជីវកម្មអ្នក



**០២**

ជៀសវាងការផាកពិន័យផ្សេងៗ
និងការតម្រូវឱ្យបិទទ្វារ
អាជីវកម្ម



**០៣**

ទទួលបានការគាំពារ
តាមផ្លូវច្បាប់



**០៤**

ទាក់ទាញអតិថិជន (ក្រុមហ៊ុនធំ) ដែលបញ្ជាទិញក្នុងទំហំធំ ព្រោះគ្មានក្រុមហ៊ុនធំណាចង់រកស៊ីជាមួយអាជីវកម្មដែលមិនចុះបញ្ជីនោះទេ



**០៥**

ជួយសម្រួលដល់ការទទួលកម្ចីប្រាក់ពីធនាគារ និងការវិនិយោគពីវិនិយោគិន



**០៦**

ទទួលបានអត្ថប្រយោជន៍ផ្សេងៗសម្រាប់និយោជិតរបស់អ្នកពីបេឡាជាតិរបបសន្តិសុខសង្គម



**០៧**

បំពេញកាតព្វកិច្ចជាពលរដ្ឋក្រោមច្បាប់ និងបទប្បញ្ញត្តិនៃប្រទេសកម្ពុជា



## ទិដ្ឋភាពរួមនៃការចុះបញ្ជីអាជីវកម្មតាមនីតិវិធីចាស់ និងថ្មី

ការចុះបញ្ជីអាជីវកម្មមួយអាចពាក់ព័ន្ធជាមួយក្រសួង-ស្ថាប័នច្រើន ប៉ុន្តែជាទូទៅ ក្រសួង-ស្ថាប័នគោលដែលពាក់ព័ន្ធរួមមានក្រសួងពាណិជ្ជកម្ម, អគ្គនាយកដ្ឋានពន្ធដារ, និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ដើម្បីដំណើរការអាជីវកម្មបានដោយស្របច្បាប់ អ្នកដែលជាម្ចាស់អាជីវកម្មត្រូវចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម រួចបន្តចុះបញ្ជីពន្ធដារនៅអគ្គនាយកដ្ឋានពន្ធដារ និងធ្វើសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាសនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ដោយឡែកអាជីវកម្មមួយចំនួនត្រូវចុះបញ្ជី ឬសុំការអនុញ្ញាតពីក្រសួង-ស្ថាប័នដទៃបន្ថែមទៀតដែលអាចជាក្រសួងទេសចរណ៍(សម្រាប់ភោជនីយដ្ឋាន)

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (សម្រាប់ក្រុមហ៊ុនសំណង់) និងក្រសួងសុខាភិបាល (សម្រាប់ឱសថស្ថាន ឬមន្ទីរពេទ្យ) ជាដើម។

តាមគោលការណ៍ចាស់ អ្នកត្រូវទៅចុះបញ្ជីអាជីវកម្មរបស់អ្នកនៅក្រសួង-ស្ថាប័នផ្សេងៗគ្នា និងតាមនីតិវិធីខុសៗគ្នា។ ការចុះបញ្ជីអាជីវកម្មមួយអាចចំណាយពេលវេលារង់ចាំច្រើនដង ទម្រាំក្រសួង-ស្ថាប័ននីមួយៗផ្ដល់ការអនុញ្ញាត។ ចំណែកប្រព័ន្ធចុះបញ្ជីរបស់ក្រសួង-ស្ថាប័ននីមួយៗមានលក្ខណៈដាច់ដោយឡែកពីគ្នា និងមិនអាចផ្សារភ្ជាប់ ផ្លាស់ប្ដូរទិន្នន័យគ្នាបាន ដែលតម្រូវឱ្យអ្នកបំពេញព័ត៌មានដដែលៗលើពាក្យស្នើសុំផ្សេងគ្នានៅក្រសួង-ស្ថាប័នផ្សេងគ្នា។

រូបភាព ១ នីតិវិធីនៃការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន




សម្រាប់ការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មីនេះ អ្នកអាចធ្វើការចុះបញ្ជីពាណិជ្ជកម្ម ចុះបញ្ជីពន្ធដារ និងធ្វើសេចក្ដីប្រកាសជូនដំណឹងបើកសហគ្រាសក្នុងពេលតែមួយបាននៅលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានតែមួយ (សូមមើលរូបភាព១ នីតិវិធីនៃការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន)។ ដោយឡែក ក្នុងដំណាក់កាលដំបូងនេះ ការចុះបញ្ជី ឬសុំការអនុញ្ញាតពី

ក្រសួង-ស្ថាប័នដទៃ ក្រៅពីក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនឹងតម្រូវឱ្យអ្នកធ្វើតាមនីតិវិធីដដែលរបស់ក្រសួង-ស្ថាប័នសាមី។ តាមរយៈដំណើរការចុះបញ្ជីថ្មីនេះ ការចុះបញ្ជីអាជីវកម្មមួយអាចចំណាយពេលយ៉ាងយូរ ៨ថ្ងៃនៃថ្ងៃធ្វើការ និងត្រូវបង់ថ្លៃសេវាតិចជាងមុន។ អ្នកក៏អាចទូទាត់សងប្រាក់សេវាទាំងអស់ក្នុងការចុះបញ្ជីអាជីវកម្មតាមអនឡាញដោយប្រើប្រាស់សេវា ABA Pay សម្រាប់អតិថិជនធនាគារវឌ្ឍនៈអាស៊ីចំកាត់ (ABA) និងតាមកាតឥណទាន ឬកាតឥណពន្ធសម្រាប់អតិថិជនធនាគារផ្សេងទៀត។ ក្រោយការចុះបញ្ជីអាជីវកម្មជោគជ័យ អ្នកនឹងទទួលបានអាជ្ញាបណ្ណ និងវិញ្ញាបនបត្រក្នុងទម្រង់ឌីជីថលតាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់យើងខ្ញុំ (សូមមើលតារាង១ ប្រៀបធៀបការចុះបញ្ជីអាជីវកម្មតាមនីតិវិធីចាស់ និងថ្មី)។

| បញ្ហាប្រឈមដែលបានកើតឡើងពីមុន | អត្ថប្រយោជន៍ដែលទទួលបានពីប្រព័ន្ធបច្ចុប្បន្ន |
|---|---|
| • ផ្តល់ព័ត៌មានដដែលៗរាល់ពេលចុះបញ្ជីនៅក្រសួង-ស្ថាប័ននីមួយៗ<br>• ចុះឈ្មោះនៅក្រសួង-ស្ថាប័នច្រើនតាមនីតិវិធីខុសៗគ្នា<br>• រង់ចាំច្រើនដង ទម្រាំក្រសួង-ស្ថាប័ននីមួយៗផ្តល់ការអនុញ្ញាត<br>• មានប្រព័ន្ធចុះបញ្ជីដាច់ដោយឡែក និងមិនអាចផ្សារភ្ជាប់គ្នាបាន<br>• ចំណាយថវិកាច្រើន | • ចំណាយពេលវេលារង់ចាំយ៉ាងយូរ ៨ថ្ងៃនៃធ្វើការ<br>• លុបបំបាត់ការផ្តល់ព័ត៌មានដដែលៗ<br>• ចំណាយថវិកាតិចជាងមុនច្រើន<br>• ទូទាត់សងប្រាក់សេវាទាំងអស់ក្នុងពេលតែមួយតាមអនឡាញ<br>• ទទួលបានអាជ្ញាបណ្ណ និងវិញ្ញាបនបត្រក្នុងទម្រង់ឌីជីថល |

តារាង១ ប្រៀបធៀបការចុះបញ្ជីអាជីវកម្មតាមនីតិវិធីចាស់ និងថ្មី

## ទម្រង់សហគ្រាស



ដំណើរការនៃការចុះបញ្ជីអាជីវកម្មដំបូងនឹងតម្រូវឱ្យអ្នកដែលជាម្ចាស់អាជីវកម្មទៅចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្មជាមុនសិន។ ក្នុងដំណាក់កាលនេះ អ្នកត្រូវដឹងច្បាស់ពីទម្រង់របស់សហគ្រាសខ្លួន។ ចំណេះដឹងនៃទម្រង់សហគ្រាសនឹងធ្វើឱ្យអ្នកអាចបំពេញទម្រង់បែបបទចុះបញ្ជីពាណិជ្ជកម្មបានត្រឹមត្រូវ។

ទម្រង់សហគ្រាសមានបួនទម្រង់ធំៗ ដែលទម្រង់នីមួយៗមានចរិតលក្ខណៈខុសៗគ្នាដូចខាងក្រោម (សូមមើលតារាង ២ សង្ខេបទម្រង់សហគ្រាស)៖

១. **ក្រុមហ៊ុនមូលធន៖** មានពីរទ្រង់ទ្រាយ គឺក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។ លក្ខណៈរបស់ក្រុមហ៊ុនមូលធនមានដូចខាងក្រោម៖

- ជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត
- ម្ចាស់ភាគហ៊ុនទទួលខុសត្រូវត្រឹមចំនួនភាគហ៊ុនដែលខ្លួនបានទិញ
- ជានីតិបុគ្គលដាច់ដោយឡែកពីម្ចាស់
- គ្រប់គ្រង និងដឹកនាំដោយក្រុមប្រឹក្សាភិបាល
- បង្កើតដោយលក្ខន្តិកៈ។

ភាពខុសគ្នារវាងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត គឺស្ថិតនៅត្រង់ថាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតអាចបោះចេញមូលបត្រលក់ជាសាធារណៈបាន។

២. **ក្រុមហ៊ុនបរទេស៖** មានបីទ្រង់ទ្រាយគឺ សាខាក្រុមហ៊ុនបរទេស ការិយាល័យតំណាងពាណិជ្ជកម្ម និងបុត្រសម្ព័ន្ធ។ ក្រុមហ៊ុនបរទេសគឺ

- ជាក្រុមហ៊ុនបង្កើតឡើងក្រោមច្បាប់នៃប្រទេសដទៃ
- មានទីតាំងពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ជាភ្នាក់ងារក្រុមហ៊ុនដើម
- ពុំមាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីក្រុមហ៊ុនដើមឡើយចំពោះសាខាក្រុមហ៊ុនពាណិជ្ជកម្ម និងការិយាល័យតំណាងពាណិជ្ជកម្ម
- ត្រូវចុះបញ្ជីក្នុងទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធនចំពោះបុត្រសម្ព័ន្ធ។

៣. **សហគ្រាសឯកបុគ្គល៖** ជាប្រភេទសហគ្រាសដែល

- មានម្ចាស់តែម្នាក់
- ទទួលខុសត្រូវគ្មានកម្រិត
- គ្មាននីតិបុគ្គល
- ទ្រព្យនិងបំណុលរបស់សហគ្រាស និងទ្រព្យនិងបំណុលបុគ្គល គឺជាទ្រព្យតែមួយ។

៤. **ក្រុមហ៊ុនសហកម្មសិទ្ធិ៖** មានពីរទ្រង់ទ្រាយដូចជា ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។ ក្រុមហ៊ុនសហកម្មសិទ្ធិគឺ

- ជាក្រុមហ៊ុនទទួលខុសត្រូវគ្មានកម្រិត
- បង្កើតឡើងដោយកិច្ចសន្យាដែលមានបុគ្គលពីរនាក់ឡើងទៅ
- ជានីតិបុគ្គល
- គ្រប់គ្រងដោយសហកម្មសិទ្ធករទូទៅទាំងអស់។

| ទម្រង់សហគ្រាស | | | | | | | |
|---|---|---|---|---|---|---|---|
| ក្រុមហ៊ុនមូលធន | | ក្រុមហ៊ុនបរទេស | | | សហគ្រាសឯកបុគ្គល | ក្រុមហ៊ុនសហកម្មសិទ្ធិ | |
| ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត | ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត | សាខាក្រុមហ៊ុនបរទេស | ការិយាល័យតំណាងពាណិជ្ជកម្ម | បុត្រសម្ព័ន្ធ[៩] | | ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ | ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត |

តារាង ២ សេចក្ដីសង្ខេបទម្រង់សហគ្រាស



## ប្រភេទអ្នកជាប់ពន្ធ

បន្ទាប់ពីការចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម អ្នកត្រូវចុះបញ្ជីពន្ធដារនៅអគ្គ-នាយកដ្ឋានពន្ធដារ។ គ្រប់អាជីវកម្មទាំងអស់មានកាតព្វកិច្ចបង់ពន្ធចូលថវិកាជាតិ តាមរបបស្វ័យប្រកាសផ្អែកតាមទំហំផលរបរប្រចាំឆ្នាំរបស់សហគ្រាស។ ផលរបរសំដៅដល់តម្លៃនៃការផ្គត់ផ្គង់ទំនិញ ឬសេវាដែលជាសកម្មភាពអាជីវកម្មរបស់អ្នកជាប់ពន្ធ។ ការយល់ដឹងអំពីប្រភេទអ្នកជាប់ពន្ធនឹងអនុញ្ញាតឱ្យអ្នកយល់ច្បាស់ពីតម្លៃសេវាចុះបញ្ជីពន្ធដារ ពេលដែលចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

[៩] រាល់ក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវចុះបញ្ជីក្នុងទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធន។

អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវបានបែងចែកជា ៣ប្រភេទរួមមាន (សូមមើលតារាង ៣ ប្រភេទអ្នកជាប់ពន្ធ)៖

| អ្នកជាប់ពន្ធតូច | អ្នកជាប់ពន្ធមធ្យម | អ្នកជាប់ពន្ធធំ |
|---|---|---|
| • ជាសហគ្រាសដែលមានផលរបរប្រចាំឆ្នាំចាប់ពី ២៥០លានរៀល (ប្រហែល ៦២៥០០ ដុល្លាអាមេរិក) ដល់ ៧០០លានរៀល (១៧៥ ០០០ ដុល្លាអាមេរិក) ឬ<br>• មានផលរបរក្នុងរយៈពេល ៣ខែជាប់គ្នាណាមួយ ដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តចាប់ពី ៦០លានរៀល (ប្រហែល ១៥ ០០០ដុល្លាអាមេរិក) ឡើងទៅ ឬ<br>• រំពឹងថាមានផលរបរក្នុងរយៈពេល ៣ខែជាប់គ្នាខាងមុខចាប់ពី ៦០លានរៀល (ប្រហែល ១៥ ០០០ដុល្លាអាមេរិក) ឡើងទៅ ឬ<br>• ចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នងថ្លៃក្នុងការផ្គត់ផ្គង់ទំនិញ ឬសេវារួមទាំងភាស៊ី។ | • ជាសហគ្រាសដែលមានផលរបរប្រចាំឆ្នាំលើសពី ៧០០លានរៀល (ប្រហែល ១៧៥ ០០០ដុល្លាអាមេរិក) ដល់ ៤០០០លានរៀល (ប្រហែល ១ លានដុល្លាអាមេរិក) ឬ<br>• ជាសហគ្រាសដែលបានចុះបញ្ជីជានីតិបុគ្គល ការិយាល័យតំណាង។ | • ជាសហគ្រាសដែលមានផលរបរប្រចាំឆ្នាំលើសពី ៤០០០លានរៀល (ប្រហែល ១ លានដុល្លាអាមេរិក) ឬ<br>• ជាបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនពហុជាតិ សាខាក្រុមហ៊ុនបរទេស ឬ<br>• ជាសហគ្រាសដែលបានចុះបញ្ជីជាគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ |

តារាង ៣ ប្រភេទអ្នកជាប់ពន្ធ



## ឯកសារភ្ជាប់

រាល់ឯកសារភ្ជាប់ទាំងអស់ត្រូវស្ថិតក្នុងទម្រង់ pdf រីឯរូបថតត្រូវស្ថិតក្នុងទម្រង់ jpg ឬ jpeg ដែលស្កេនពីច្បាប់ដើម ហើយមានគុណភាពល្អ។ សូមបញ្ជាក់ថា ប្រសិនបើអ្នកមិនផ្តល់ឯកសារឬព័ត៌មានគ្រប់គ្រាន់ និងច្បាស់លាស់ក្នុងពេលអ្នកចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់យើង អ្នកអាចនឹងប្រឈមការបដិសេធលើសំណើចុះបញ្ជី។ ក្នុងករណីនេះ រាល់ការចំណាយដែលបានធ្វើឡើងលើប្រព័ន្ធនេះនឹងមិនមានការធានាចំពោះការប្រគល់ប្រាក់ជូនវិញនោះទេ។

### ១ សម្រាប់ក្រុមហ៊ុនមូលធន

ក. ការចុះបញ្ជីពាណិជ្ជកម្មត្រូវការឯកសារដូចខាងក្រោម៖

- ☑ ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម *
- ☑ រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ០៣ ខែ និងមានផ្ទៃខាងក្រោយពណ៌សរបស់អភិបាល, ម្ចាស់ហ៊ុន (ករណីម្ចាស់ហ៊ុនជារូបវន្តបុគ្គល) និង/ឬ អ្នកតំណាង (ករណីម្ចាស់ហ៊ុនជានីតិបុគ្គល) *
- ☑ ឯកសារអត្តសញ្ញាណប័ណ្ណរបស់អភិបាល, ម្ចាស់ហ៊ុន (ករណីម្ចាស់ហ៊ុនជារូបវន្តបុគ្គល) និង/ឬ អ្នកតំណាង (ករណីម្ចាស់ហ៊ុនជានីតិបុគ្គល) *
- ☑ លក្ខន្តិកៈក្រុមហ៊ុន *
- ☑ ឯកសារយោង (អាចជាលិខិតអនុញ្ញាតប្រើប្រាស់នាមករណ៍របស់ក្រុមហ៊ុនចាស់ អាជ្ញាបណ្ណផ្សេងៗចេញដោយក្រសួង-ស្ថាប័នជំនាញ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត)
- ☑ ករណីម្ចាស់ហ៊ុនជានីតិបុគ្គល
  - ❑ លិខិតប្រគល់សិទ្ធិពីក្រុមហ៊ុនមេ *
  - ❑ វិញ្ញាបនបត្រក្រុមហ៊ុនមេ *
  - ❑ លក្ខន្តិកៈក្រុមហ៊ុនមេ *
- ☑ លិខិតប្រគល់សិទ្ធិករណីអ្នកតំណាងជាអ្នកបំពេញពាក្យស្នើសុំ

ខ. ការចុះបញ្ជីពន្ធដារត្រូវការឯកសារដូចខាងក្រោម៖

- ☑ លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យរបស់សហគ្រាស
- ☑ ករណីក្រុមហ៊ុនទទួលបានគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP)

- ☑ ព័ត៌មានអំពីគណនីធនាគារ (ត្រូវផ្តល់ក្នុងរយៈពេល**១៥ថ្ងៃនៃថ្ងៃធ្វើការ**បន្ទាប់ពីបានការទទួលការចុះបញ្ជីពន្ធដារតាមទម្រង់ឌីជីថល។ ក្នុងករណីខកខានមិនបានផ្តល់ព័ត៌មាននេះការផ្តល់ការចុះបញ្ជីពន្ធដារត្រូវបានដកហូតដោយស្វ័យប្រវត្តិ។)

## ២ សម្រាប់ក្រុមហ៊ុនបរទេស

### ក. ការចុះបញ្ជីពាណិជ្ជកម្មត្រូវការឯកសារដូចខាងក្រោម៖

- ☑ ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម *
- ☑ រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ០៣ ខែ និងមានផ្ទៃខាងក្រោយពណ៌របស់នាយក *
- ☑ ឯកសារអត្តសញ្ញាណប័ណ្ណរបស់នាយក *
- ☑ លក្ខន្តិកៈក្រុមហ៊ុនមេ *
- ☑ វិញ្ញាបនបត្រក្រុមហ៊ុនមេ *
- ☑ លិខិតប្រគល់សិទ្ធិតែងតាំងនាយកការិយាល័យតំណាង ឬនាយកសាខា *
- ☑ ឯកសារយោង (អាចជាលិខិតអនុញ្ញាតប្រើប្រាស់នាមករណ៍របស់ក្រុមហ៊ុនចាស់ អាជ្ញាបណ្ណផ្សេងៗចេញដោយក្រសួង-ស្ថាប័នជំនាញ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត)
- ☑ លិខិតប្រគល់សិទ្ធិករណីអ្នកតំណាងជាអ្នកបំពេញពាក្យស្នើសុំ

### ខ. ការចុះបញ្ជីពន្ធដារត្រូវការឯកសារដូចខាងក្រោម៖

- ☑ លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យរបស់សហគ្រាស
- ☑ ករណីក្រុមហ៊ុនទទួលបានគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP)
- ☑ ព័ត៌មានអំពីគណនីធនាគារ (ត្រូវផ្តល់ក្នុងរយៈពេល**១៥ថ្ងៃនៃថ្ងៃធ្វើការ**បន្ទាប់ពីបានការទទួលការចុះបញ្ជីពន្ធដារតាមទម្រង់ឌីជីថល ក្នុងករណីខកខានមិនបានផ្តល់ព័ត៌មាននេះការផ្តល់ការចុះបញ្ជីពន្ធដារត្រូវបានដកហូតដោយស្វ័យប្រវត្តិ។)

## ៣ សម្រាប់សហគ្រាសឯកបុគ្គល

### ក. ការចុះបញ្ជីពាណិជ្ជកម្មត្រូវការឯកសារដូចខាងក្រោម៖

- ☑ ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម *
- ☑ រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ០៣ ខែ និងមានផ្ទៃខាងក្រោយពណ៌សរបស់ម្ចាស់សហគ្រាស *
- ☑ ឯកសារអត្តសញ្ញាណប័ណ្ណរបស់ម្ចាស់សហគ្រាស *
- ☑ ឯកសារយោង (អាចជាលិខិតអនុញ្ញាតប្រើប្រាស់នាមករណ៍របស់ក្រុមហ៊ុនចាស់ អាជ្ញាបណ្ណផ្សេងៗចេញដោយក្រសួង-ស្ថាប័នជំនាញ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត)
- ☑ លិខិតប្រគល់សិទ្ធិករណីអ្នកតំណាងជាអ្នកបំពេញពាក្យស្នើសុំ

ខ. ការចុះបញ្ជីពន្ធដារត្រូវការឯកសារដូចខាងក្រោម៖

- ☑ លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យរបស់សហគ្រាស
- ☑ ករណីក្រុមហ៊ុនទទួលបានគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP)
- ☑ ព័ត៌មានអំពីគណនីធនាគារ (ត្រូវផ្តល់ក្នុងរយៈពេល**១៥ថ្ងៃនៃថ្ងៃធ្វើការ**បន្ទាប់ពីបានការទទួលការចុះបញ្ជីពន្ធដារតាមទម្រង់ឌីជីថល ក្នុងករណីខកខានមិនបានផ្តល់ព័ត៌មាននេះ ការផ្តល់ការចុះបញ្ជីពន្ធដារត្រូវបានដកហូតដោយស្វ័យប្រវត្តិ។)

## ៤ សម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិ

ក. ការចុះបញ្ជីពាណិជ្ជកម្មត្រូវការឯកសារដូចខាងក្រោម៖

- ☑ ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម *
- ☑ រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ០៣ ខែ និងមានផ្ទៃខាងក្រោយពណ៌ស របស់អ្នកគ្រប់គ្រង, សហកម្មសិទ្ធករ (ករណីសហកម្មសិទ្ធករជារូបវន្តបុគ្គល) និង/ឬ អ្នកតំណាង (ករណីសហកម្មសិទ្ធករជានីតិបុគ្គល) *
- ☑ ឯកសារអត្តសញ្ញាណប័ណ្ណរបស់អ្នកគ្រប់គ្រង, សហកម្មសិទ្ធករ (ករណីសហកម្មសិទ្ធករជារូបវន្តបុគ្គល) និង/ឬ អ្នកតំណាង (ករណីសហកម្មសិទ្ធករជានីតិបុគ្គល) *
- ☑ កិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិ *
- ☑ ឯកសារយោង (អាចជាលិខិតអនុញ្ញាតប្រើប្រាស់នាមករណ៍របស់ក្រុមហ៊ុនចាស់ អាជ្ញាបណ្ណផ្សេងៗចេញដោយក្រសួង-ស្ថាប័នជំនាញ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត)
- ☑ ករណីសហកម្មសិទ្ធករជានីតិបុគ្គល
  - ❑ លិខិតប្រគល់សិទ្ធិពីក្រុមហ៊ុនមេ *
  - ❑ វិញ្ញាបនបត្រក្រុមហ៊ុនមេ *
  - ❑ លក្ខន្តិកៈក្រុមហ៊ុនមេ *
- ☑ លិខិតប្រគល់សិទ្ធិករណីអ្នកតំណាងជាអ្នកបំពេញពាក្យស្នើសុំ

ខ. ការចុះបញ្ជីពន្ធដារត្រូវការឯកសារដូចខាងក្រោម៖

- ☑ លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យរបស់សហគ្រាស
- ☑ ករណីក្រុមហ៊ុនទទួលបានគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP)
- ☑ ព័ត៌មានអំពីគណនីធនាគារ (ត្រូវផ្តល់ក្នុងរយៈពេល**១៥ថ្ងៃនៃថ្ងៃធ្វើការ**បន្ទាប់ពីបានការទទួលការចុះបញ្ជីពន្ធដារតាមទម្រង់ឌីជីថល ក្នុងករណីខកខានមិនបានផ្តល់ព័ត៌មាននេះ ការផ្តល់ការចុះបញ្ជីពន្ធដារត្រូវបានដកហូតដោយស្វ័យប្រវត្តិ។)



# តម្លៃសេវាចុះបញ្ជីអាជីវកម្ម

ទំហំនៃការចំណាយក្នុងការចុះបញ្ជីអាជីវកម្ម អាចខុសគ្នាទៅតាមទម្រង់សហគ្រាស ប្រភេទសេវា និងចំណាត់ថ្នាក់អ្នកជាប់ពន្ធ (សូមមើលតារាង ៤ តម្លៃសេវាចុះបញ្ជីអាជីវកម្ម)។

| ក្រសួង-ស្ថាប័ន | ប្រភេទនៃសេវា | តម្លៃសេវា (គិតជាពាន់រៀល) | | | |
|---|---|---|---|---|---|
| | | ក្រុមហ៊ុនមូលធន | ក្រុមហ៊ុនបរទេស | សហគ្រាសឯកបុគ្គល | ក្រុមហ៊ុនសហកម្មសិទ្ធិ |
| ក្រសួងពាណិជ្ជកម្ម | បម្រុងទុកនាមករណ៍ក្រុមហ៊ុន សហគ្រាស | ២៥ | ២៥ | ២៥ | ២៥ |
| | ចុះបញ្ជីពាណិជ្ជកម្ម | ១,០១០ | ១,០១០ | ១៨០ | ១,០១០ |
| | សរុប (គិតជាពាន់រៀល) | ១,០៣៥ | ១,០៣៥ | ២០៥ | ១,០៣៥ |
| | ប៉ាន់ស្មានសរុប (គិតជាដុល្លារអាមេរិច) | ២៥៨.៧៥ | ២៥៨.៧៥ | ៥១.២៥ | ២៥៨.៧៥ |

| ក្រសួង-ស្ថាប័ន | ប្រភេទនៃសេវា | តម្លៃសេវា (គិតជាពាន់រៀល) | | | |
|---|---|---|---|---|---|
| | | ពន្ធតូច | ពន្ធមធ្យម | ពន្ធធំ | |
| | | | | ៤ ពាន់លានរៀល < ផលរបរ > ១០ពាន់លានរៀល | ផលរបរ > ១០ពាន់លានរៀល |
| អគ្គនាយកដ្ឋានពន្ធដារ | ចុះបញ្ជីពន្ធដារ | ២០ | ៤០០ | ៤០០ | ៤០០ |
| | ពន្ធប៉ាតង់ក្នុងមួយសកម្មភាពអាជីវកម្ម[២] | ២០០ | ៦០០ | ១,៥០០ | ២,៥០០ |
| | សរុប (គិតជាពាន់រៀល) | ២២០ | ១,០០០ | ១,៩០០ | ២,៩០០ |
| | ប៉ាន់ស្មានសរុប(គិតជាដុល្លារអាមេរិច) | ៥៥ | ២៥០ | ៤៧៥ | ៧២៥ |

[២] ក្នុងគោលដៅលើកទឹកចិត្ត និងជំរុញការចុះបញ្ជីអាជីវកម្មក្នុងប្រទេសកម្ពុជាអ្នកជាប់ពន្ធគ្រប់ប្រភេទត្រូវបង់ពន្ធប៉ាតង់ត្រឹមតែ ៥០%នៃប្រាក់ពន្ធប៉ាតង់ប៉ុណ្ណោះ សម្រាប់ឆ្នាំដំបូងក្រោយការចុះបញ្ជីអាជីវកម្ម។ អ្នកជាប់ពន្ធនឹងត្រូវបង់ពេញថ្លៃ (ពីរដងនឹងតម្លៃខាងលើ) នៅឆ្នាំបន្តបន្ទាប់។

| ក្រសួង-ស្ថាប័ន | ប្រភេទនៃសេវា | តម្លៃសេវា (គិតជាពាន់រៀល) |
|---|---|---|
| | | រាល់ទម្រង់សហគ្រាស |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ការពិនិត្យ និងទទួលសេចក្តីប្រកាសបញ្ជិកាសហគ្រាសពីម្ចាស់សហគ្រាស | ១២០ |
| | សរុប (គិតជាពាន់រៀល) | ១២០ |
| | ប៉ាន់ស្មានសរុប (គិតជាដុល្លារអាមេរិច) | ៣០ |

តារាង ៤ តម្លៃសេវាចុះបញ្ជីអាជីវកម្ម

# ផ្នែកទី ២

# ចុះបញ្ជីអាជីវកម្មអ្នកតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន



## ដំណើរការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

ដំណើរការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានចែកចេញជា ៦ជំហានធំៗ៖

០១
ការបង្កើតគណនីលើ CamDigiKey App

០២
ការ Log In ចូលទំព័រ Portal

០៣
ដំណើរការចុះបញ្ជី



០៤
ការទូទាត់ប្រាក់



០៥
ការពិនិត្យស្ថានភាព និងទទួលបានសារជូនដំណឹងពីកំហុសផ្សេងៗក្នុងដំណាក់-កាលនីមួយៗ



០៦
ការទទួលបានអាជ្ញាបណ្ណ/វិញ្ញាបនបត្រឌីជីថល។




## ១. ការបង្កើតគណនីលើ CamDigiKey App[៣]

១.១. ដោនឡូត CamDigiKey App ពី App Store ឬ Play Store លើទូរស័ព្ទដៃរបស់អ្នក។

[៣] CamDigiKey គឺជាកម្មវិធីទូរស័ព្ទសម្រាប់ផ្ទៀងផ្ទាត់អត្តសញ្ញាណតាមរយៈ QR Code របស់រាជរដ្ឋាភិបាលកម្ពុជា ដែលភ្ជាប់អ្នកប្រើប្រាស់ទៅសេវាកម្មរដ្ឋាភិបាលឌីជីថលរបស់ប្រទេសកម្ពុជា។




១.២. ចូលទៅកាន់ CamDigiKey App រួចចុចប៊ូតុង "ចុះឈ្មោះ"។

១.៣. បញ្ចូលលេខទូរស័ព្ទដែរបស់អ្នកទៅក្នុង App នោះ លេខកូដស្វ័យប្រវត្តិនឹងត្រូវបានផ្ញើទៅកាន់លេខទូរស័ព្ទដែរបស់អ្នក។

១.៤. វាយលេខកូដនោះចូលក្នុង App ដើម្បីបញ្ជាក់លេខទូរស័ព្ទដែរបស់អ្នក។

១.៥. បង្កើតលេខកូដផ្ទាល់ខ្លួនចំនួន ៦ខ្ទង់។












១.៦. បំពេញព័ត៌មានអត្តសញ្ញាណរបស់អ្នក។

១.៧. បំពេញថ្ងៃខែឆ្នាំកំណើត ភេទ និងទីកន្លែងកំណើត។

១.៨. បំពេញអាសយដ្ឋានបច្ចុប្បន្នរបស់អ្នក។

១.៩. បំពេញព័ត៌មានអត្តសញ្ញាណប័ណ្ណ (សម្រាប់សញ្ជាតិខ្មែរ) ឬលិខិតឆ្លងដែន (សម្រាប់សញ្ជាតិបរទេស)។












១.១០. វាយលេខកូដមួយផ្សេងទៀតដែលបានផ្ញើទៅកាន់សារអេឡិចត្រូនិចរបស់អ្នកទៅក្នុង App ដើម្បីបញ្ជាក់សារអេឡិចត្រូនិចរបស់អ្នក។

១.១១. បញ្ចូលរូបថតអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នក។

១.១២ ចុច "ថតរូប" រួចថតរូបរបស់អ្នក។

១.១៣. រង់ចាំយ៉ាងយូរ ២៤ម៉ោងសម្រាប់ការត្រួតពិនិត្យ។

១.១៤. អ្នកបានបង្កើតគណនី CamDigiKey ដោយជោគជ័យ។









## ២. ការ Log In ចូលទំព័រ Portal

២.១. ចូលទៅតំណ www.registrationservices.gov.kh លើកុំព្យូទ័ររបស់អ្នក, រួចចុចលើប៊ូតុង "ចុះបញ្ជីអាជីវកម្ម" នៅជ្រុងខាងស្ដាំផ្នែកខាងលើនៃគេហទំព័រ។




២.២. ចុចប៊ូតុង "ទាញយក QR Code" ។






២.៣. ស្កេន QR Code ដែលអ្នកឃើញជាមួយនឹង CamDigiKey App នៅលើទូរស័ព្ទដៃរបស់អ្នក។

២.៤. បញ្ចូលលេខកូដផ្ទាល់ខ្លួនចំនួន ៦ខ្ទង់ដែលអ្នកបានបង្កើតក្នុង CamDigiKey App ទៅក្នុង CamDigiKey App នោះ អ្នកនឹងចូលទៅកាន់ទំព័រ Portal ចុះបញ្ជីអាជីវកម្មក្នុងកុំព្យូទ័រដោយស្វ័យប្រវត្តិ។

## ៣. ដំណើរការចុះបញ្ជី

៣.១. ចុចប៊ូតុង "ចុះបញ្ជីអាជីវកម្ម"។



៣.២. ជ្រើសរើសទម្រង់សហគ្រាសដែលសមស្របទៅនឹងសហគ្រាសរបស់អ្នក រួចបំពេញព័ត៌មាន និងភ្ជាប់ឯកសារលើទម្រង់បែបបទ "ចុះបញ្ជីពាណិជ្ជកម្ម" រួចចុច "បន្ទាប់"។



៣.៣. បំពេញព័ត៌មាន និងភ្ជាប់ឯកសារលើទម្រង់បែបបទ "ចុះបញ្ជីពន្ធដារ" រួចចុច "បន្ទាប់"។



### ៣.៤. បំពេញព័ត៌មាន និងភ្ជាប់ឯកសារលើទម្រង់បែបបទ "សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស" រួចចុច "បន្ទាប់"។



### ៣.៥. ពិនិត្យព័ត៌មាន និងឯកសារឡើងវិញ រួចចុចប៊ូតុង "ដាក់ស្នើ"។



## ៤. ការទូទាត់សងប្រាក់

៤.១. ជ្រើសរើសជម្រើសទូទាត់សងប្រាក់មួយ ដែលក្នុងនោះមាន ABA Pay និងការទូទាត់តាមរយៈកាតឥណទាន ឬកាតឥណពន្ធ។

៤.២. ក្នុងករណីទូទាត់ប្រាក់តាម ABA Pay,

៤.២.១. អ្នកនឹងឃើញ QR Code នៅលើអេក្រង់កុំព្យូទ័រ។

៤.២.២. ចូលទៅកាន់ ABA Mobile App រួច log in គណនីធនាគារ ABA របស់អ្នកលើទូរស័ព្ទដៃ។

៤.២.៣. ចុចប៊ូតុង "ស្កេន QR" នៅលើ ABA Mobile App។

៤.២.៤. ស្កេន QR Code ដែលបង្ហាញនៅលើអេក្រង់កុំព្យូទ័រជាមួយទូរស័ព្ទដៃរបស់អ្នក។

៤.២.៥. ការទូទាត់សងប្រាក់ និងការចុះបញ្ជីអាជីវកម្មរបស់អ្នកត្រូវបានបញ្ចប់។

៤.៣. ក្នុងករណីទូទាត់សងប្រាក់តាមកាតឥណទាន ឬកាតឥណពន្ធ (Visa, Master Card ឬ Union Pay International)[៣],

៤.៣.១. បំពេញព័ត៌មានគណនីរបស់អ្នក រួចចុចប៊ូតុង "ដាក់ស្នើ"។

៤.៣.២. ការទូទាត់សងប្រាក់ និងការចុះបញ្ជីអាជីវកម្មរបស់អ្នកត្រូវបានបញ្ចប់។




៣ រាល់ការទូទាត់សងប្រាក់តាមកាតឥណទាន ឬកាតឥណពន្ធនឹងត្រូវមានការបង់ថ្លៃសេវាបន្ថែម (additional service charge) ទៅលើតម្លៃសរុប ២.៣%។

## ៥. ការពិនិត្យស្ថានភាព និងទទួលបានសារជូនដំណឹងពីកំហុសផ្សេងៗក្នុងដំណាក់កាលនីមួយៗ

៥.១. ពេល Log in ចូលទំព័រ Portal ចុច “ក្រុមហ៊ុនរបស់ខ្ញុំ”។




៥.២. ចុចលើក្រុមហ៊ុនណាមួយដែលអ្នកចង់តាមដានស្ថានភាពសំណើ នោះអ្នកនឹងឃើញមានការបញ្ជាក់ស្ថានភាពសំណើលម្អិត។



# ៦. ការទទួលបានអាជ្ញាបណ្ណ/វិញ្ញាបនបត្រឌីជីថល

៦.១. នៅពេលដែលអ្នកឃើញព័ត៌មានអំពីស្ថានភាពលម្អិតរបស់ក្រុមហ៊ុនអ្នក សូមចុច “ទាញយក” នៅក្នុងផ្នែកវិញ្ញាបនបត្រ។






# សេវាកម្មផ្សេងទៀតក្រៅពីការចុះបញ្ជីអាជីវកម្ម

**ចង់បម្រុងទុកនាមករណ៍ក្រុមហ៊ុនមែនទេ?** អ្នកអាចបម្រុងទុកនាមករណ៍ក្រុមហ៊ុនតាម ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដោយគ្រាន់តែ Log in ចូលទំព័រ Portal, ចុចប៊ូតុង "បម្រុងទុកនាមករណ៍ក្រុមហ៊ុន" រួចចុចប៊ូតុង "បង្កើតនាមករណ៍បម្រុងទុក" ដើម្បីបំពេញទម្រង់បែបបទជាការស្រេច។

ក្នុងករណីចង់បម្រុងទុកនាមករណ៍ស្រដៀងគ្នាទៅនឹងនាមករណ៍របស់ក្រុមហ៊ុនដែលបានចុះបញ្ជីរួច អ្នកត្រូវភ្ជាប់លិខិតអនុញ្ញាតប្រើប្រាស់នាមករណ៍របស់ក្រុមហ៊ុនចាស់ ប្រសិនបើមាន។

**ចង់ស្នើសុំគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មែនទេ?** អ្នកក៏អាចស្នើសុំគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) បានដែរដោយគ្រាន់តែចូលទៅគេហទំព័រ www.registrationservices.gov.kh រួចចុច "ស្នើសុំ QIP" នៅជ្រុងខាងស្តាំផ្នែកខាងលើនៃគេហទំព័រ។ អ្នកនឹងចូលទៅកាន់ទម្រង់បែបបទនៃពាក្យស្នើសុំ។

# ជំនួយបន្ថែម

## ប្រព័ន្ធចុះបញ្ជីអាជីវកម្ម


អាសយដ្ឋាន: ផ្លូវលេខ ៩២, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ, ប្រទេសកម្ពុជា

www.registrationservices.gov.kh

(+៨៥៥) ៨១ ៨៨៨ ២៩៦

registrationservices@mef.gov.kh

ការជជែកផ្ទាល់

Online Business Registration Services

Online Business Registration Services


## គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់


(+៨៥៥) ៩៩ ៧៩៩ ៥៧៩ / ៩៨ ៧៩៩ ៥៧៩



Powered by CamDX
www.camdx.gov.kh




Powered by CamDX

ដំណាក់កាលបច្ចុប្បន្ន

ដំណាក់កាលបន្ទាប់